ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ



# ស្ថិតិសហគមន៍ព្រៃឈើកម្ពុជា ឆ្នាំ២០១៣

ខែមិថុនា ឆ្នាំ២០១៣

# អារម្ភកថា

ធនធានព្រៃឈើដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនិងបរិស្ថាន ជាពិសេសបានផ្តល់សារប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់សង្គមជាតិយើងតាំងពីដើមរហូតមកដល់បច្ចុប្បន្ននិងទៅអនាគត។ព្រៃឈើជួយថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិធ្វើឲ្យធាតុអាកាស មានភាពកាន់តែប្រសើរឡើងធ្វើឲ្យខ្យល់បរិសុទ្ធរក្សាបាននូវនិយ័តភាពប្រភពទឹកការពារទីជម្រាលនិងជីវចម្រុះព្រមទាំងចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នទៅបរិយាកាស និងជួយទ្រទ្រង់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋរាប់លាននាក់ដែលពឹងអាស្រ័យទៅលើផលអនុផលព្រៃឈើ។ហេតុនេះប្រជាពលរដ្ឋគ្រប់រូបត្រូវមានកាតព្វកិច្ចថែរក្សាការពារប្រភពទ្រទ្រង់ជីវិតដោយត្រូវចូលរួមថែរក្សាការពារអភិរក្សនិអភិវឌ្ឍព្រៃឈើឲ្យមានប្រសិទ្ធភាពនិងនិរន្តរភាពដើម្បីជាប្រយោជន៍ដល់មនុស្សជាតិយើងជំនាន់បច្ចុប្បន្ននិងជំនាន់ក្រោយៗ ទៀត។

ដោយសារធនធានព្រៃឈើផ្តល់នូវសារប្រយោជន៍យ៉ាងធំធេងបែបនេះរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តកម្មវិធីកំណែទម្រង់ព្រៃឈើដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលបានចាត់ទុកការងារសហគមន៍ព្រៃឈើជាការងារអាទិភាពក្នុងការគ្រប់គ្រងព្រៃឈើ។

រដ្ឋបាលព្រៃឈើមានសេចក្តីសោមនស្សរីករាយ សូមបង្ហាញនូវទិន្នន័យសហគមន៍ព្រៃឈើនៅកម្ពុជា តាមរយៈសៀវភៅ "**ស្ថិតិសហគមន៍ព្រៃឈើកម្ពុជាឆ្នាំ២០១៣**" សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំកម្មវិធី និងផែនការសកម្មភាពអភិវឌ្ឍសហគមន៍ព្រៃឈើក៏ដូចជាការអភិវឌ្ឍ ការអភិរក្ស ការសិក្សាស្រាវជ្រាវការប្រើប្រាស់ផល អនុផលព្រៃឈើ និងសេវាកម្មផ្សេងៗទៀត។

រដ្ឋបាលព្រៃឈើមានកិត្តិយសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះស្ថាប័នពាក់ព័ន្ធអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍នានា សង្គមស៊ីវិលជាតិនិងអន្តរជាតិ និងសហគមន៍មូលដ្ឋានដែលចូលរួមឧបត្ថម្ភ គាំទ្រដល់ដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើនៅកម្ពុជាប្រកបដោយជោគជ័យ និងសូមថ្លែងអំណរគុណយ៉ាងអនេកចំពោះ អង្គការដៃគូទាំងអស់ដែលបានចូលរួមឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅស្ថិតិនេះ។

**ឆេង គឹមស៊ុន**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## ២.៧. សហគមន៍ព្រៃឈើនៅខេត្តកំពង់ស្ពឺ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ៥៥១ប្រក.កសក. ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ និងប្រកាសលេខ០៨០ប្រក.កសក. ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ស្ពឺ។

### តារាង៩ ៖ ស្ថិតិសហគមន៍ព្រៃឈើខេត្តកំពង់ស្ពឺ, មិថុនា ២០១៣

| ល.រ | ឈ្មោះ ស.ព | ផ្ទៃដីព្រៃ (ហ.ត) | ឃុំ | ស្រុក | ចំនួនភូមិ | គ្រួសារសមាជិក | ថ្ងៃ ខែ ឆ្នាំ ក.ស.ក | ថ្ងៃ ខែ ឆ្នាំ កិច្ចព្រម |
|---|---|---|---|---|---|---|---|---|
| ១ | ចំបក់ | ២៨៦ | ចំបក់ | ភ្នំស្រួច | ៣ | ១៩៦ | ២០.០៨.១០ | ១៩.១០.១១ |
| ២ | ចង្អោរតូច | ៩២៥ | ស្រង់ | គងពិសី | ៩ | ២១៩ | ២០.០៨.១០ | ០៩.១២.១០ |
| ៣ | ដីក្រហមគិរីវ័ន្ត | ៦៥ | គិរីវ័ន្ត | ភ្នំស្រួច | ២ | ២០៨ | ២០.០៨.១០ | ១៩.១០.១១ |
| ៤ | ដីក្រហមមហាសាំង | ១៥៤ | មហាសាំង | ភ្នំស្រួច | ៥ | ៤៤៧ | ២០.០៨.១០ | ១៩.១០.១១ |
| ៥ | កំពូលពេជ្រ | ១១៩ | គិរីវ័ន្ត | ភ្នំស្រួច | ២ | ២៤៤ | ២០.០៨.១០ | ១៩.១០.១១ |
| ៦ | កន្ទួតជ្រុំ | ៣៧ | គិរីវ័ន្ត | ភ្នំស្រួច | ១ | ៥៧ | ២០.០៨.១០ | ១៩.១០.១១ |
| ៧ | គិរីរស្មីដីដុះ | ១៣៩ | តាំងស្យា | ភ្នំស្រួច | ៣ | ២៦០ | ២០.០៨.១០ | ១៩.១០.១១ |
| ៨ | ក្រាំងសេរី | ៩៣ | គិរីវ័ន្ត | ភ្នំស្រួច | ១ | ៥៧ | ២០.០៨.១០ | ០៩.១២.១០ |
| ៩ | ក្រូចបួង | ៣៥១ | ជាំសង្កែ | ភ្នំស្រួច | ១ | ១៦៦ | ២០.០៨.១០ | ០៩.១២.១០ |
| ១០ | លាបគុយ | ១០៧ | តាំងសំរោង | ភ្នំស្រួច | ៣ | ១៨៥ | ២០.០៨.១០ | ១៩.១០.១១ |
| ១១ | ភ្នំស្រង់ | ២.៤០៦ | ស្រង់ | គងពិសី | ១៤ | ១.៣២៤ | ២០.០៨.១០ | ០៩.១២.១០ |
| ១២ | រាំងពេន | ១៩១ | ព្រៃរំដួល | ភ្នំស្រួច | ៧ | ៦១៩ | ២០.០៨.១០ | ១៩.១០.១១ |
| ១៣ | ស្វាយរំពារ | ៩១៣ | ស្វាយរំពារ | បរសេដ្ឋ | ៦ | ៥៧៥ | ២០.០៨.១០ | ០៩.១២.១០ |
| ១៤ | តាំងបំពង់ | ២៤០ | តាសាល | ឱរ៉ាល់ | ១ | ៥០ | ២០.០៨.១០ | ០៤.១២.១១ |
| ១៥ | ទ័ពមាន | ៣៥១ | ទ័ពមាន | ថ្ពង់ | ៦ | ២៨៦ | ២០.០៨.១០ | ០៤.១២.១១ |
| ១៦ | សែនមនោរម្យ | ៤៤៧ | ហោងសំណំ | ឱរ៉ាល់ | ១ | ៨២ | ១៩.០២.១៣ | |
| ១៧ | ដំរីចាក់ធ្លក | ១.៤៥២ | ក្រាំងដីវ៉ាយ | ភ្នំស្រួច | ១ | ១៨៣ | ១៩.០២.១៣ | |
| ១៨ | ជ្រោះដំបង | ៥០៤ | ជាំសង្កែ | ភ្នំស្រួច | ១ | ១០៣ | ១៩.០២.១៣ | |
| ១៩ | អូរព្រិច | ៦៦០ | ហោងសំណំ | ឱរ៉ាល់ | ៣ | ១៨២ | | |
| ២០ | អូរព្រានមក | ១.៧០៥ | សង្កែសាទប | ឱរ៉ាល់ | ៤ | ២៦៧ | | |
| ២១ | អមលាំង | ៩០៦ | អមលាំង | ថ្ពង | ៣ | ២១៥ | | |
| ២២ | ប្រាំបីមុំ | ៨៦២ | ប្រាំបីមុំ | ថ្ពង | ១ | ២៦៧ | | |
| ២៣ | ភ្នំពញ្ញាគង់ | ៤៨៩ | ស្វាយចចិត្រ | បរសេដ្ឋ | ១ | ១១២ | | |
| ២៤ | ចង្អោរធំ | ៦២២ | ស្វាយចចិត្រ | បរសេដ្ឋ | ១ | ១៨០ | | |
| ២៥ | ជ្រោះដំរៃ | ២៥៥ | ស្វាយចចិត្រ | បរសេដ្ឋ | ១ | ៧០ | | |
| សរុប | | ១៣.៧៧៩ | ១៨ | ៥ | ៧៦ | ៦.៥០៤ | ១៨ | ១៥ |

## រូបភាពទី៩ ៖ ផែនទីទីតាំងព្រៃសហគមន៍ខេត្តកំពង់ស្ពឺ, មិថុនា ២០១៣




## ២.៨. សហគមន៍ព្រៃឈើនៅខេត្តកំពត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ៥៤៩ប្រក.កសក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ ប្រកាសលេខ៦១០ប្រក.កសក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ និងប្រកាសលេខ០៧៥ ប្រក.កសក ចុះថ្ងៃទី១៩ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត។

### តារាង១០ ៖ ស្ថិតិសហគមន៍ព្រៃឈើខេត្តកំពត, មិថុនា ២០១៣

| ល.រ | ឈ្មោះ ស.ព | ផ្ទៃដីព្រៃ (ហ.ត) | ឃុំ | ស្រុក | ចំនួនភូមិ | គ្រួសារសមាជិក | ថ្ងៃ ខែ ឆ្នាំ ក.ស.ក | ថ្ងៃ ខែ ឆ្នាំ កិច្ចព្រម |
|---|---|---|---|---|---|---|---|---|
| ១ | ភ្នំចងឯក | ៦៩ | តាកែន | ឈូក | ១ | ១០០ | ២០.០៨.១០ | ១៥.០៨.១១ |
| ២ | ព្រៃខ្មៅ | ១៩៧ | ស្រែក្នុង | ជុំគិរី | ១ | ១៩៣ | ២០.០៨.១០ | ១៦.១២.១០ |
| ៣ | ត្រពាំងស្តៅ | ៣៩១ | ត្រពាំងភ្លាំង | ឈូក | ១ | ២២៥ | ២០.០៨.១០ | ១៥.០៨.១១ |
| ៤ | ថ្មសរូងខ្លា | ៥៩០ | ស្រែចែង | ជុំគិរី | ៣ | ១.១៣៩ | ២០.០៨.១០ | ១៦.១២.១០ |
| ៥ | ដំណាក់អ្នកតាថ្មពូន | ៩៨៥ | ស្រែក្នុង | ជុំគិរី | ៣ | ៧៨៥ | ២០.០៨.១០ | ១៦.១២.១០ |
| ៦ | ដំណាក់លោះបរថ្មធំ | ៥៨៧ | ស្រែសំរោង | ជុំគិរី | ៥ | ៩៧០ | ២០.០៨.១០ | ១៦.១២.១០ |
| ៧ | ភ្នំធំចំណងសាមគ្គី | ១.០១៥ | តាកែន | ឈូក | ១ | ២១៦ | ២០.០៨.១០ | ១៥.០៨.១១ |
| ៨ | ជ្រោះកង្កែប | ៨៥ | ព្រៃឃ្មុំ | ទឹកឈូ | ២ | ៩៩១ | ០៥.១២.១១ | ២៦.០៤.១២ |
| ៩ | ភ្នំគូបធ្យូង | ១២១ | ព្រៃថ្នង | ទឹកឈូ | ១ | ២៣៣ | ០៥.១២.១១ | ២៦.០៤.១២ |
| ១០ | ព្រែកត្នោត | ១.០០៧ | ព្រែកត្នោត | ទឹកឈូ | ៤ | ៩៦៩ | ០៥.១២.១១ | ២៦.០៤.១២ |